# CPC : ហោរាចារ្យ អ៊ឹម បុរិន្ទ្រ ថ្លែងថា ហោរាចារ្យ ប៊ុន វាស្នារ ធ្វើអំពើដ៏អាក្រក់ក្បត់ទំនុកចិត្តមិត្តរួមការងារដែលមិនអាចអត់ឱនឲ្យបានឡើយ

ថ្ងៃទី21 ខែ February ឆ្នាំ2022

ភ្នំពេញ៖ហោរាចារ្យ អ៊ឹម បុរិន្ទ្រ ទីប្រឹក្សាអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ថ្លែងថា ហោរាចារ្យ ប៊ុន វាស្នារ ជំនួយការអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ធ្វើនូវអំពើដ៏អាក្រក់ក្បត់ទំនុកចិត្តមិត្តរួមការងារដែលមិនអាចអត់ឱនឲ្យបានឡើយ ពាក់ព័ន្ធទៅនឹងការថតចម្លងខ្លឹមសារសៀវភៅតម្រាព្យាករណ៍ លក់ជាសាធារណៈដែលមិនមែនជាស្នាដៃនិពន្ធរបស់ខ្លួន ។

**យោងតាមលិខិតជូនដំណឹងរបស់មេធាវីនិងយោងតាមគណនីហ្វេសប៊ុករបស់ ហោរាចារ្យ អ៊ឹម បុរិន្ទ្រ មានខ្លឹមសារទាំងស្រុងថា ៖**

ខ្ញុំបាទ អ៊ឹម បុរិន្ទ ទីប្រឹក្សាអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិអន្តរជាតិ

ខ្ញុំបាទសូមគោរពជម្រាបជូនបងប្អូនជនរួមជាតិក្នុងបណ្តាញសង្គម ហ្វេសបុក តេលេក្រាម ជាទីរាប់ អានមេត្តាជ្រាបថា មួយរយៈកន្លងទៅនេះ ឯកឧត្តមប៊ុន វាស្នារ ជំនួយការអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិអន្តរជាតិបានបោះពុម្ពសៀវភៅ (តម្រាព្យាករណ៍ លេខអត្ថៈ ៧តួ៩ថាន) លក់ជាសាធារណៈ។ ខ្ញុំបាទបានទិញយកមកមើលទើបដឹងថាខ្លឹមសារក្នុងសៀវភៅនេះសុទ្ធតែបានចម្លងពីសៀវភៅ (ព្រហ្មលិខិតពិស្តារ)និងឯកសារជា Excel របស់ខ្ញុំ ដែលឯកឧត្តម ប៊ុន វាស្នារ សុំពីខ្ញុំយកទៅសម្រាប់សិក្សា ដោយយល់ថាគាត់ជាមិត្តរួមការងារជាមួយនិងជាអ្នកហោរាដូចគ្នាទើបជូនទៅគាត់។ តែផ្ទុយទៅវិញគាត់បែរជាក្បត់ទំនុកចិត្តយកឯកសារនោះទៅបោះពុម្ពលក់និងផ្សព្វផ្សាយតាម Page សមាគមស្រាវជ្រាវវិជ្ជាហោរាសាស្ត្រ Page បណ្ណាល័យហោរាសាស្ត្រ តាមFacebook ឈ្មោះ Heng Ty ចាត់ទុកជាឯកសាររបស់ខ្លួន ដោយមិនមានការសុំអនុញ្ញាតិពីខ្ញុំសោះឡើយ។

ក្នុងមួយរយៈកន្លងទៅនេះខ្ញុំបានទុកពេលឱ្យគាត់ចូលមកដោះស្រាយតែគាត់មិនបានចូលមកទេ។ ខ្ញុំបានឱ្យមេធាវីរបស់ខ្ញុំធ្វើលិខិតអញ្ជើញគាត់នៅថ្ងៃទី១៦ខែកុម្ភៈ២០២២វេលាម៉ោង៣រសៀលគាត់នៅតែគេចវេសមិនព្រមចូលមកដោះស្រ័យដដែល។

អាស្រ័យហេតុនេះខ្ញុំបាទសូមជម្រាបជូនបងប្អូនមេត្តាជ្រាបថានេះអំពើដ៏អាក្រក់ក្បត់ទំនុកចិត្តមិត្តរួមការងាររបស់ឯកឧត្តម ប៊ុន វាស្នារ ដែលមិនអាចអត់ឱនឱ្យបានឡើយ និងសូមឱ្យឯកឧត្តម ប៊ុន វាស្នារនិងបក្ខពួក

បញ្ឈប់រាល់ការបោះពុម្ពនិងចែកចាយសៀវភៅដែលមានជាប់ពាក់ព័ន្ធឯកសារដែលជាស្នាដៃរបស់ខ្ញុំនិង បញ្ឈប់រាល់ការយករបស់អ្នកដទៃមកក្រឡៃធ្វើជារបស់ខ្លួនឯង។

នៅមានសៀវភៅពីរក្បាលទៀតដែលគាត់បានបោះពុម្ពដែរដែលគាត់បានចម្លងពីឯកសាររបស់ខ្ញុំដែរនោះ មាន៖

១-ប្រជុំទំនៀមក្បួនតម្រាខ្មែរ បានយកឯកសារ(តារាសាស្ត្រខ្មែរ តម្រាមហានាទី)របស់ខ្ញុំចំនួន២៤ទំព័រនិង យកលំនាំដោយកែតួលេខ៣៣ទំព័រ និងដកពីសៀវភៅ (វិធីគណនាប្រតិទិនខ្មែរ.សកល៨០០ឆ្នាំ)មួយចំនួន ទៀតព្រមទាំងយកលំនាំគំនិតដោយកែតួលេខជាច្រើនទំព័រទៀត។

២-ប្រតិទិនប្រចាំឆ្នាំ បានចម្លងចេញពីសៀវភៅ(មហាសង្ក្រានឆ្នាំខាលឆ្នាំ២០២២) (តម្រាព្យាករណ៍ជោគ ជតារាសី) បោះពុម្ពឆ្នាំ២០០៣និង(មហាសង្ក្រានឆ្នាំខាលទោស័ក២០១០)ដែលសុទ្ធតែជាសៀវភៅរបស់ ខ្ញុំ បាទសរុបទាំងអស់ចំនួន៤៧ទំព័រក្នុងសៀវភៅ១០៣ទំព័រ







៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមមេធាវីអន្តរជាតិ ខេ ធី អិល
KTL INTERNATIONAL LAW GROUP

លេខ:០១៣)........ខ.ធ.អ
២០២២

*ថ្ងៃអង្គារ ៧កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥*
*រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២២*

## ក្រុមមេធាវី អន្តរជាតិ ខេ ធី អិល

## <u>ជំរាបជូន</u>

## លោក ប៊ុន វាសនា

ដែលមានទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១៥ជេ ភូមិ០៤ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ។
លេខទូរស័ព្ទ ០១២ ៤៤៤ ៥៥៥ . ០៨៩ ៤៤៤ ៥៥៥ .០១៦ ៦១ ៨១ ៩១

<u>កម្មវត្ថុ:</u> សូមអញ្ជើញ **លោក** ចូលមកកាន់ការិយាល័យ **ក្រុមមេធាវី អន្តរជាតិ ខេ ធី អិល** នៅថ្ងៃទី **១៦-០២-២០២២** វេលាម៉ោង **៣:០០** រសៀល ដើម្បីធ្វើការដោះស្រាយពាក់ពន្ធ័នឹងសៀវភៅតម្រាព្យាករណ៍ លេខអត្ថ: ៧តួ ៩ឋាន ។

<u>យោង:</u> -លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី ០៨-០២-២០២២។

- សៀវភៅ តម្រាព្យាករណ៍ លេខ ៧តួ ៩ឋាន។
- ឯកសារជា soft Excel ចំនួន ១៨២ ទំព័រ ។
- សៀវភៅព្រហ្មលិខិតពិស្ដារ ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំជំរាបជូន **លោក** ជ្រាបថា÷ អំឡុង ខែឧសភា ឆ្នាំ២០២០ **លោក** បានមកសុំឯកសារលេខអត្ថ: ៧តួ ៩ឋាន ជាទំរង់ soft Excel ចំនួន ១៨២ ទំព័រ ពីកូនក្ដីខ្ញុំ ដើម្បីយកទៅសិក្សារៀនសូត្រ ដោយគិតថាជាមនុស្សស្គាល់គ្នា និងជាអ្នកធ្វើការជាមួយគ្នាផង កូនក្ដីខ្ញុំក៏សំរេចចិត្តអោយឯកសារលេខអត្ថ: ៧តួ ៩ឋាន ជាទំរង់ soft Excel ចំនួន ១៨២ ទំព័រ ទៅ **លោក** ។ តែក្រោយមក នៅអំឡុង ខែធ្នូ ឆ្នាំ២០២១ កូនក្ដីខ្ញុំបានឃើញមានការបោះពុម្ពសៀវភៅតម្រាព្យាករណ៍លេខអត្ថ: ៧ តួ ៩ឋាន ចែកចាយលក់នៅលើទីផ្សារ និងមានការបង្ហោះលក់ជាសាធារណៈតាម Page របស់សមាគមស្រាវជ្រាវវិជ្ជាហោរាសាស្ត្រ . តាម Facebook ដែលមានឈ្មោះ Heng Ty និងតាម Facebook ដែលមានឈ្មោះ Bun veasna ជាដើម.....។ ដោយឃើញមានការដាក់លក់នៅលើទីផ្សារ និងតាមបណ្ដាញសង្គម Facebook ជាច្រើននោះ កូនក្ដីខ្ញុំបានទិញសៀវភៅតម្រាព្យាករណ៍លេខអត្ថ: ៧ តួ ៩ឋាន យកមកមើល ទើបបានដឹងថាខ្លឹមសារអត្ថបទនៅក្នុង សៀវភៅតម្រាព្យាករណ៍លេខអត្ថ: ៧ តួ ៩ឋាន ដែលមានចំនួន ១៧៩ ទំព័រ ក្នុងនោះបានដកស្រង់ខ្លឹមសារតាម soft Excel របស់កូនក្ដីខ្ញុំ មានចំនួន ១៣០ ទំព័រ និងដកស្រង់ខ្លឹមសារតាម សៀវភៅព្រហ្មលិខិតពិស្ដារ របស់កូនក្ដីខ្ញុំ មានចំនួន ១៤៩ ទំព័រ ។ ហេតុនេះ សូម **លោក** ចូលមកកាន់ការិយាល័យ **ក្រុមមេធាវី អន្តរជាតិ ខេ ធី អិល** ដែលមាន

ទីស្នាក់ការ ៖ ផ្ទះលេខ ៣១បេ-៣១សេ ផ្លូវលេខ ៣៨៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ទូរស័ព្ទ ៖ ០២៣ ៦៦៦ ០៣ ០៩ / ០២៣ ៥០០ ១៥ ៥៧
#31B-31C, St. 384, Sangkat Toul Svayprey I, Khan Beoung Keng Kang, Phnom Penh, Cambodia. Tel: 023 666 03 09 / 023 500 15 57

BLACKSHARK 3 PRO
AI TRIPLE CAMERA

ទីតាំងស្ថិត នៅ ផ្ទះលេខ ៣១បេ ផ្លូវលេខ ៣៨៤ សង្កាត់ ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ នៅថ្ងៃទី **១៦-០២-២០២២** វេលាម៉ោង **៣:០០ រសៀល** ដើម្បីធ្វើការដោះស្រាយពាក់ពន្ធ័នឹង សៀវភៅតម្រាព្យាករណ៍លេខអត្ថ: ៧តួ ៩ឋាន ជាកំហិត។

អាស្រ័យហេតុនេះ សូម **លោក** អញ្ជើញមកតាមកម្មវត្ថុខាងលើ ជាកំហិត ។

សូម **លោក** ទទួលនូវការរាប់អានពីខ្ញុំ ។

*<u>ចំលងជូន:</u>*
*- ឈ្មោះ អ៊ឹម បុរិន្ទ ចំនួន ០១ច្បាប់ ។*
*"ដើម្បីជ្រាប"*

**ហត្ថលេខា និងត្រា**

**មេធាវី.ស៊ា_ទណ្ឌរ័ត**

បានទទួល
ថ្ងៃទី០៩.០២.ឆ្នាំ២០២២

ប៊ុន វាសនា

BLACKSHARK 3 PRO
AI TRIPLE CAMERA

# ប្រជុំទំនៀមក្បួនតម្រាខ្មែរ

ស្រាវជ្រាវនិងរៀបរៀងដោយៈ



ហោរាចារ្យ ប៊ុន វាស្នារ

ជំនួយការអម គណៈកម្មាធិការជាតិ
រៀបចំបុណ្យជាតិ-អន្តរជាតិ
និងជាសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការស្រាវជ្រាវ
វិជ្ជាហោរាសាស្ត្រ ប្រពៃណីទំនៀមទម្លាប់ខ្មែរ

ច.ស.១៣៨៣

ព.ស.២៥៦៥

Scanned with CamScanner

# ប្រតិទិនប្រចាំឆ្នាំ

## សុរិយគតិ-ចន្ទគតិខ្មែរ ឆ្នាំខាល

## ចត្វាស័ក ព.ស.២៥៦៦ គ.ស.២០២២



មហាសង្ក្រាន្ត
ប្រតិទិន
បកសករាជ
សម្ពុជ្ជផ្កាយ
ពិធីជាមង្គល-អពមង្គល

Scanned with CamScanner

រក្សាសិទ្ធិ

បោះពុម្ពលើកទី ១




Scanned with CamScanner

**អ៊ឹម បុរិន្ទ្រ អ្នកហោរាសាស្ត្រខ្មែរ**

February 18 at 10:53 AM ·

ខ្ញុំបាទ អ៊ឹម បុរិន្ទ ទីប្រឹក្សាអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិអន្តរជាតិ

ខ្ញុំបាទសូមគោរពជម្រាបជូនបងប្អូនជនរួមជាតិក្នុងបណ្តាញសង្គម ហ្វេសបុក គេលេក្រាម ជាទីរាប់ អានមេត្តាជ្រាបថា មួយរយៈកន្លងទៅនេះ ឯកឧត្តមប៊ុន វាស្នារ ជំនួយការអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិអន្តរជាតិបានបោះពុម្ពសៀវភៅ (តម្រាព្យាករណ៍លេខអត្ថ: ៧តួ៩ឋាន) លក់ជាសាធារណៈ។ ខ្ញុំបាទបានទិញយកមកមើលទើបដឹងថាខ្លឹមសារក្នុងសៀវភៅនេះសុទ្ធតែបានចម្លងពីសៀវភៅ (ព្រហ្មលិខិតពិស្តារ)និងឯកសារជា Excel របស់ខ្ញុំ ដែលឯកឧត្តម ប៊ុន វាស្នារ សុំពីខ្ញុំយកទៅសម្រាប់សិក្សា ដោយយល់ថាគាត់ជាមិត្តរួមការងារជាមួយនិងជាអ្នកហោរាដូចគ្នាទើបជូនទៅគាត់។ តែផ្ទុយទៅវិញគាត់បែរជាក្បត់ទំនុកចិត្តយកឯកសារនោះទៅបោះពុម្ពលក់និងផ្សព្វផ្សាយតាម Page សមាគមស្រាវជ្រាវវិជ្ជាហោរាសាស្ត្រ Page បណ្ណាល័យហោរាសាស្ត្រ តាមFacebook ឈ្មោះ Heng Ty ចាត់ទុកជាឯកសាររបស់ខ្លួន ដោយមិនមានការសុំអនុញ្ញាតិពីខ្ញុំសោះឡើយ។

ក្នុងមួយរយៈកន្លងទៅនេះខ្ញុំបានទុកពេលឱ្យគាត់ចូលមកដោះស្រាយតែគាត់មិនបានចូលមកទេ។ ខ្ញុំបានឱ្យមេធាវីរបស់ខ្ញុំធ្វើលិខិតអញ្ជើញគាត់នៅថ្ងៃទី១៦ខែកុម្ភៈ២០២២វេលាម៉ោង៣រសៀលគាត់នៅតែគេចវេសមិនព្រមចូលមកដោះស្រ័យដដែល។

អាស្រ័យហេតុនេះខ្ញុំបាទសូមជម្រាបជូនបងប្អូនមេត្តាជ្រាបថានេះអំពើអាក្រក់ក្បត់ទំនុកចិត្តមិត្តរួមការងាររបស់ឯកឧត្តម ប៊ុន វាស្នារ ដែលមិនអាចអត់ឱនឱ្យបានឡើយ និងសូមឱ្យឯកឧត្តម ប៊ុន វាស្នារនិងបក្ខពួកបញ្ឈប់រាល់ការបោះពុម្ពនិងចែកចាយសៀវភៅដែលមានជាប់ពាក់ព័ន្ធឯកសារដែលជាស្នាដៃរបស់ខ្ញុំនិង បញ្ឈប់រាល់ការយករបស់អ្នកដទៃមកក្រឡៃធ្វើជារបស់ខ្លួនឯង។

នៅមានសៀវភៅពីរក្បាលទៀតដែលគាត់បានបោះពុម្ពដែរដែលគាត់បានចម្លងពីឯកសាររបស់ខ្ញុំដែរនោះមាន៖

១-ប្រជុំទំនៀមក្បួនតម្រាខ្មែរ បានយកឯកសារ(តារាសាស្ត្រខ្មែរ តម្រាមហានាទី)របស់ខ្ញុំចំនួន២៩ទំព័រនិងយកលំនាំដោយកែតួលេខ៣៣ទំព័រ និងដកពីសៀវភៅ (វិធីគណនាប្រតិទិនខ្មែរ.សកល៨០០ឆ្នាំ)មួយចំនួនទៀតព្រមទាំងយកលំនាំគំនិតដោយកែតួលេខជាច្រើនទំព័រទៀត។

២-ប្រតិទិនប្រចាំឆ្នាំ បានចម្លងចេញពីសៀវភៅ(មហាសង្ក្រានឆ្នាំខាលឆ្នាំ២០២២) (តម្រាព្យាករណ៍ជោគជតារាសី) បោះពុម្ពឆ្នាំ២០០៣និង(មហាសង្ក្រានឆ្នាំខាលទោស័ក២០១០)ដែលសុទ្ធតែជាសៀវភៅរបស់ ខ្ញុំបាទសរុបទាំងអស់ចំនួន៤៧ទំព័រក្នុងសៀវភៅ១០៣ទំព័រ។